ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ:......................អ.ជ.ប.ជ.អ

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# កម្ពុជាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលUNAIDS លើកទី៥៣

គណៈប្រតិភូកម្ពុជាដែលដឹកនាំដោយឯកឧត្ដមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលUNAIDS លើកទី៥៣ (53rd UNAIDS PCB meeting) ដែលប្រព្រឹត្តទៅនៅថ្ងៃទី១២-១៤ ខែធ្នូ ឆ្នាំ២០២៣ នាទីក្រុងហ្សឺណែវ ប្រទេសស្វីស។

នៅព្រឹកថ្ងៃទី១២ ខែធ្នូ ដែលជាថ្ងៃទី១នៃកិច្ចប្រជុំ បន្ទាប់ពីនាយិកាប្រតិបត្តិUNAIDS លោកស្រី Winnie Byanyima បានធ្វើរបាយការណ៍រួចមក ឯកឧត្ដមទេសរដ្ឋមន្ត្រី អៀង មូលី ត្រូវបានអញ្ជើញផ្ដល់មតិជាវាគ្មិនទីមួយ។ ឯកឧត្ដមទេសរដ្ឋមន្ត្រីបានលើកចំណុចមួយចំនួនរួមមាន ៖ ១) កម្ពុជាបានរៀបចំកម្មវិធីអេដស៍ ដោយយកប្រជាជនជាស្នូល គឺអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនងាយរងគ្រោះជាស្នូល ជាត្រីកោណដែលមាន អ្នកចេញគោលនយោបាយ អ្នកផ្ដល់សេវា និងសហគមន៍ធ្វើការរួមគ្នា ២) កម្ពុជាជាប្រទេសតែមួយគត់ដែលអង្គភាពរដ្ឋាភិបាលធ្វើការយ៉ាងជិតស្និទ្ធ ជាមួយសង្គមស៊ីវិល ជាពិសេសអ្នកផ្ទុកមេរោគអេដស៍ ប្រជាជនគន្លឹះ ជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ ៣) កម្ពុជាបានបង្កើនថវិកាបដិភាគក្នុងមូលនិធិសកលបានជាង៦០% ដើម្បីទិញឱសថប្រឆាំងមេរោគអេដស៍ (៥លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០២១ ២០២២ និង ២០២៣ ៤) កម្ពុជាកំពុងផ្ដល់អត្ថប្រយោជន៍នៃកម្មវិធីគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ៥) កម្ពុជាបានសម្រេចគោលដៅ៩០-៩០-៩០រួចហើយនៅឆ្នាំ២០១៧ មុនកាលកំណត់ (ឆ្នាំ២០២០) និង៦) ចំពោះគោលដៅបញ្ចប់អេដស៍៩៥-៩៥-៩៥ កម្ពុជាសម្រេចបាន៨៦-៩៩-៩៨ បានន័យថា កម្ពុជាបានសម្រេចគោលដៅ២លើគោលដៅ៣រួចទៅហើយគឺ ៖ ៩៥ទី២ និង៩៥ទី៣។

ក្រោយពីបានស្ដាប់មតិចូលរួមពីគណៈប្រតិភូទាំងអស់មក លោកស្រីនាយិកាប្រតិបត្តិបានបូកសរុបដោយចាប់ផ្ដើមពីការលើកសរសើរកម្ពុជា និងបានវាយតម្លៃថា កម្មវិធីអេដស៍នៅកម្ពុជាអាចជាគំរូមួយក្នុងពិភពលោក ជាពិសេសការយកចិត្តទុកដាក់ផ្ដល់ការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងបើកទ្វារឱ្យសង្គមស៊ីវិលចូលរួមឆ្លើយតបមេរោគអេដស៍នៅគ្រប់លំដាប់ថ្នាក់។ លោកស្រីនាយិកាប្រតិបត្តិ


អាសយដ្ឋាន: អគារលេខ១៦ ផ្លូវលេខ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ទូរស័ព្ទ (855) 23 885 109 និង 023 885 129
Tel: (855) 23 885 109 / 023 885 129 E-mail: info@naaa.gov.kh Website: naaa.gov.kh

យល់ថាកម្ពុជាអាចឈានទៅសម្រេចគោលដៅបញ្ចប់អេដស៍៩៥-៩៥-៩៥ ព្រោះថាបានសម្រេចគោលដៅ៩៥ពីររួចហើយ នៅខ្វះតែ៩៥ទីមួយប៉ុណ្ណោះ។

នៅរសៀលថ្ងៃទី១២ខែធ្នូដដែលនោះ លោកស្រីនាយិកាប្រតិបត្តិបានទទួលពិភាក្សាទ្វេភាគីជាមួយគណៈប្រតិភូកម្ពុជា។ ចំណុចដែលលើកយកមកពិភាក្សារួមមាន ៖ ១) ការថ្លែងនូវការកោតសរសើររាជរដ្ឋាភិបាលកម្ពុជាដែលបានដឹកនាំកម្មវិធីអេដស៍បានល្អ សម្រេចគោលដៅ៩៥-៩៥-៩៥ បាន៨៦-៩៩-៩៨។ កម្ពុជាពិតជាអាចឈោងចាប់បានជោគជ័យបញ្ចប់អេដស៍ ប្រសិនបើខិតខំទាក់ទាញប្រជាជនគន្លឹះ ជាពិសេសយុវវ័យអាយុក្រោម៣០ឆ្នាំ អ្នករួមភេទដូចគ្នាឱ្យមកទទួលសេវាការពារថែទាំព្យាបាល ចាប់ផ្តើមពីមកធ្វើតេស្តឈាម និងប្រើវិធីបង្ការឱ្យខ្លាំងក្លាថែមទៀត។ ការផ្តល់អត្ថប្រយោជន៍នៃកម្មវិធីគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ជាគោលនយោបាយប្រសើរបំផុតដែលកម្រមាននៅក្នុងពិភពលោក។

ឆ្លៀតឱកាសនោះ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឯកឧត្តមទេសរដ្ឋមន្ត្រីបានអញ្ជើញលោកស្រីនាយិកាប្រតិបត្តិមកធ្វើទស្សនកិច្ចនៅកម្ពុជា។ លោកស្រីទទួលយកការអញ្ជើញនេះភ្លាម ដោយសន្យាថានឹងពិភាក្សាជាមួយក្រុមការងាររបស់UNAIDS ដើម្បីជ្រើសរើសពេលវេលាណាមួយដ៏សមស្របខាងមុខ។

នៅព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ឯកឧត្តមទេសរដ្ឋមន្ត្រីបានជួបពិភាក្សាការងារជាមួយលោក Mark Edington និងលោក Urban Weber នាយកខាងផ្តល់ហិរញ្ញប្បទាន និងនាយកផ្នែកអនុវត្តកម្មវិធីនៃមូលនិធិសកល (Global Fund) នៅទីស្នាក់ការរបស់មូលនិធិសកល។ ថ្នាក់ដឹកនាំទាំងពីរក៏បានអបអរសាទរចំពោះលទ្ធផលល្អនៃកម្មវិធីអេដស៍នៅកម្ពុជា ដែលមិននាំឱ្យមូលនិធិសកលជួបលំបាកអ្វីសោះឡើយ។ ម្យ៉ាងទៀត ថ្នាក់ដឹកនាំទាំងពីររូបនៃមូលធិសកលបានបញ្ជាក់ថា ហិរញ្ញប្បទានចំនួន៤២លានដុល្លារសម្រាប់កម្មវិធីអេដស៍ និងរបេងនៅកម្ពុជាសម្រាប់៣ឆ្នាំ គឺឆ្នាំ២០២៤ ២០២៥ និង២០២៦បានចុះហត្ថលេខារួចហើយ និងអាចអនុវត្តបានចាប់ពីដើមឆ្នាំ២០២៤តទៅ។

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**